ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨០.ក្រ

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅ
នៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

សមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ត្រូវបានកែសម្រួលដូចខាងក្រោម ៖

១- ឯកឧត្តម	**លឹម គានហោ**	រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម	ប្រធាន
២- ឯកឧត្តម	**ម៉ុន ហ៊ាន**	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	អនុប្រធាន
៣- ឯកឧត្តម	**សុខុម គគនចន្ទមុនី**	រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន	អនុប្រធាន
៤- ឯកឧត្តម	**ហូ ទិចិត្រ**	រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល	សមាជិក
៥- ឯកឧត្តម	**សក់ សេដ្ឋា**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក

៦- ឯកឧត្តម	**សួង ម៉េងគា**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧- ឯកឧត្តម	**ឆាង ជុប**	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៨- ឯកឧត្តម	**ចិន សម្បត្តិថាវរ័ត្ន**	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់	សមាជិក
៩- ឯកឧត្តម	**ណៅ ធួក**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១០- ឯកឧត្តម	**ហេង សុខណាង**	អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
១១- ឧត្តមសេនីយ៍ឯក	**ងួន សារ៉ន**	ប្រធានអង្គភាពអន្តរាគមន៍ នៃអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ	សមាជិក
១២-		អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ	សមាជិក
១៣-		អភិបាល នៃគណៈអភិបាលខេត្តកណ្តាល	សមាជិក
១៤-		អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង	សមាជិក
១៥-		អភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង	សមាជិក
១៦-		អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម	សមាជិក
១៧-		អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ	សមាជិក
១៨-		អភិបាល នៃគណៈអភិបាលខេត្តក្រចេះ	សមាជិក
១៩-		អភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង	សមាជិក
២០-		អភិបាល នៃគណៈអភិបាលខេត្តរតនគីរី	សមាជិក
២១-		អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគីរី	សមាជិក
២២-		អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ	សមាជិក
២៣-		អភិបាល នៃគណៈអភិបាលខេត្តសៀមរាប	សមាជិក
២៤-		អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ	សមាជិក
២៥-		អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ	សមាជិក
២៦-		អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង	សមាជិក
២៧-		អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់	សមាជិក
២៨-		អភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង	សមាជិក
២៩-		អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ	សមាជិក
៣០-		អភិបាល នៃគណៈអភិបាលខេត្តតាកែវ	សមាជិក
៣១-		អភិបាល នៃគណៈអភិបាលខេត្តកោះកុង	សមាជិក
៣២-		អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ	សមាជិក
៣៣-		អភិបាល នៃគណៈអភិបាលខេត្តកំពត	សមាជិក
៣៤-		អភិបាល នៃគណៈអភិបាលខេត្តកែប	សមាជិក

មាត្រា ២ .-

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានភារកិច្ចដូចតទៅ ៖

- ជាសេនាធិការផ្ទាល់របស់នាយករដ្ឋមន្ត្រី ដើម្បីត្រួតពិនិត្យ និងតាមដានការធ្វើអាជីវកម្មខ្សាច់ ទាំងអាជីវកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ទាំងអាជីវកម្មសម្រាប់ការនាំចេញ
- ធ្វើការសិក្សាជលវិទ្យាជាទៀងទាត់ សម្រាប់ដាក់ឲ្យអនុវត្ត ដើម្បីសម្រួលដល់ការបូមស្តារទន្លេ ក្នុងទិសដៅសម្រួលនាវាចរណ៍ ការផ្គត់ផ្គង់សកម្មភាពសំណង់ និងបញ្ឈៀសការបាក់ច្រាំងទន្លេ ព្រមទាំងធ្វើការសិក្សាពីភាពចំណេញ និងខាត ដោយផ្អែកលើទិដ្ឋភាពបច្ចេកទេស និងសង្គមនិងសេដ្ឋកិច្ច ចំពោះការធ្វើអាជីវកម្មនាំចេញខ្សាច់សមុទ្រ ដើម្បីលើកយោបល់ ជូនរាជរដ្ឋាភិបាល
- ធ្វើការសិក្សា កំណត់ទីតាំង តាមលក្ខណៈបច្ចេកទេសច្បាស់លាស់ មុននឹងអនុញ្ញាតឲ្យធ្វើអាជីវកម្ម ទាំងខ្សាច់ក្នុងទឹក លើគោក និងទីតាំងស្តុកខ្សាច់ (ដេប៉ូ) ដោយចៀសវាងបាននូវមហន្តរាយផ្សេងៗ ដែលអាចកើតមានឡើង
- ធ្វើការសិក្សាពីលទ្ធភាពបូមដីទន្លេ ស្ទឹង ដើម្បីចាក់បំពេញបឹងបួរបម្រើដល់ការអភិវឌ្ឍ ក្នុងក្របខណ្ឌទូទាំងប្រទេស
- រៀបចំសៀវភៅបន្ទុក ដោយភ្ជាប់នូវកាតព្វកិច្ចមានជាអាទិ៍ លក្ខខណ្ឌបច្ចេកទេស ហិរញ្ញវត្ថុ បរិស្ថាន និងសង្គម
- រាល់ចំណូលទាំងអស់ ដែលប្រមូលបានត្រូវបង់ត្រង់ចូលគណនីទោលរបស់រតនាគារជាតិ
- រៀបចំដេញថ្លៃការធ្វើអាជីវកម្មខ្សាច់ តាមនីតិវិធីហិរញ្ញវត្ថុសាធារណៈជាធរមាន ។ ក្នុងករណីមានការចូលរួមតាមរូបភាពដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ត្រូវគោរពតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈជាធរមាន ដោយមានសៀវភៅបន្ទុកដែលមានវិធានច្បាស់លាស់ ក្នុងការកំណត់ពីកាតព្វកិច្ច សិទ្ធិ និងអំណាចរបស់រាជរដ្ឋាភិបាល និងរបស់ប្រតិបត្តិករឯកជន
- ពិនិត្យ និងសម្រេចផ្តល់ ឬលុបចោលនូវគោលការណ៍បច្ចេកទេស សម្រាប់ធ្វើអាជីវកម្ម របស់ក្រុមហ៊ុន អាជីវករ ដែលមិនគោរពតាមសៀវភៅបន្ទុក
- ធ្វើរបាយការណ៍ប្រចាំខែ ពីលទ្ធផលការងារ ដែលអនុវត្តបានជូនរាជរដ្ឋាភិបាល ។

មាត្រា ៣ .-

- គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម លើរាល់លិខិតស្នាម
- គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ត្រូវមានថវិកាសម្រាប់ដំណើរការរដ្ឋបាល ។ ថវិកានេះ ត្រូវស្ថិតក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងធនធានទឹក និងឧតុនិយម
- គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ត្រូវរៀបចំប្រជុំការងារជាទៀងទាត់រៀងរាល់ ០៣ (បី) ខែម្តង
- គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៤ .-

- គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានលេខាធិការដ្ឋានមួយ ដែលមានទីតាំង នៅក្នុងទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ជាជំនួយការងារ
- លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជារដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម និងជំនួយការមួយចំនួនតាមការចាំបាច់ ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រី

របស់ក្រសួងធនធានទឹក និងឧតុនិយម ឬជាមន្ត្រីក្របខណ្ឌមកពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

មាត្រា ៥ .-

លេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានភារកិច្ចដូចតទៅ ៖

- ជាសេនាធិការឲ្យគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- ទទួលរៀបចំដែនការការងារ និងកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- បំពេញការងារផ្សេងៗទៀត តាមការចង្អុល និងណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់។

មាត្រា ៦ .-

បទល្មើស ឬ ភាពអនាធិបតេយ្យ នៃការធ្វើអាជីវកម្មខ្សាច់ កើតមាននៅក្នុងភូមិសាស្ត្រាជធានី-ខេត្ត ណា អភិបាល នៃគណៈអភិបាលរាជធានី-ខេត្តនោះ ត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះមុខរាជរដ្ឋាភិបាល ។

មាត្រា ៧ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការពេជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ